មាត្រា ៤ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៩៩

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ១៣ អនក្រ.បក

### ស្តីពីការបង្កើត ចំការកៅស៊ូមេមត់

### ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១-៩៦-១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

## សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១.**_ ត្រូវបានកែប្រែអង្គភាពស្វ័យាភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូមេមត់ ឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា ចំការកៅស៊ូមេមត់ សរសេរកាត់ "ច ក ម " ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ចំការកៅស៊ូមេមត់ មានទីស្នាក់ការស្ថិតនៅឃុំខ្នងក្រពើ ស្រុកមេមត់ ខេត្តកំពង់ចាម
- ចំការកៅស៊ូមេមត់ គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

**មាត្រា ២ .**_ ចំការកៅស៊ូមេមត់ មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ ចំការកៅស៊ូមេមត់ មានភារកិច្ច និង កាតព្វកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនៈទ្រព្យ និងអចលនៈទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងស្តុន្តិធិ ការវេចខ្ចប់ ការលើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធក្នុងការធ្វើអាជីវកម្ម-ផលិតកម្ម ។

- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិដ្ឋាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

មាត្រា ៣ ._ ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ចំការកៅស៊ូមេមត់ ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ ចំការកៅស៊ូមេមត់ ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភណ្ឌរបស់ខ្លួនបានគង់វង្ស និងមានការរីកចំរើន ។

មាត្រា ៤ ._ ចំការកៅស៊ូមេមត់ បានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើតចំការកៅស៊ូមេមត់

៣-លក្ខន្តិកៈ ចំការកៅស៊ូមេមត់

៤-ច្បាប់ និងបទបញ្ជាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

មាត្រា ៥ ._ ចំការកៅស៊ូមេមត់ ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ជាជាធរមាន ។

មាត្រា ៦ ._ ដើមទុនដំបូងនៃចំការកៅស៊ូមេមត់ ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- ពេលដែលអនុក្រឹត្យនេះចូលជាធរមាន ចំការកៅស៊ូមេមត់ ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៧._ បុគ្គលិករបស់ចំការកៅស៊ូមេមត់ ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូមេមត់ ។

បុគ្គលិករបស់ ចំការកៅស៊ូមេមត់ ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ២

## ការដឹកនាំនិងគ្រប់គ្រង

មាត្រា ៨ ._ ចំការកៅស៊ូមេមត់ ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + ប្រធានអគ្គនាយក ចំការកៅស៊ូមេមត់ | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តកំពង់ចាម ឬតំណាង | ១ រូប | ជាសមាជិក |
| + តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ | ១ រូប | ជាសមាជិក |
| + តំណាងនិយោជិតរបស់ ចំការកៅស៊ូមេមត់ | ១ រូប | ជាសមាជិកស្វ័យប្រវត្តិ |

មាត្រា ៩ ._ -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនិតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត ចំការកៅស៊ូមេមត់

មាត្រា ១០ ._ ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម ចំការកៅស៊ូមេមត់ ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី ៖

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើគណនេយ្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ចំការកៅស៊ូមេមត់ ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ចំការកៅស៊ូមេមត់ ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល ចំការកៅស៊ូមេមត់ ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ ចំការកៅស៊ូមេមត់ តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ។

មាត្រា ១១ .- -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាយក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់ក្វ័រ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហារបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារក្វ័រ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២.- សេចក្តីសម្រេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក ចំការកៅស៊ូមេមត់ ។

មាត្រា ១៣.- ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ចំការកៅស៊ូមេមត់ និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

មាត្រា ១៤.- ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ ៖

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមតំណាក់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ ចំការកៅស៊ូមេមត់ ។

២-ទទួលដឹកនាំ ចំការកៅស៊ូមេមត់ លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ ចំការកៅស៊ូមេមត់ ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែងឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ ចំការកៅស៊ូមេមត់ ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ ចំការកៅស៊ូមេមត់ ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់តវ៉ាការពារក្តីឲ្យ ចំការកៅស៊ូមេមត់ និងការប្តឹងជំទាស់ផ្សេងៗ ។

មាត្រា ១៥.- លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៦ .- ការចុះ និងការអនុវត្តនៃកិច្ចសន្យាដោយចំការកៅស៊ូមេមត់ ត្រូវគោរពតាមបែបបទនិងនីតិវិធី ដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧ .- ចំការកៅស៊ូមេមត់ កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជាក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨ .- -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ ចំការកៅស៊ូមេមត់ ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ចំការកៅស៊ូមេមត់ ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ ចំការកៅស៊ូមេមត់ ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម នៃរាកម្មរបស់ ចំការកៅស៊ូមេមត់ ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ ចំការកៅស៊ូមេមត់ ។

មាត្រា ២០ ._ ធនធាននៃ ចំការកៅស៊ូមេមត់ ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ ចំការកៅស៊ូមេមត់

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ចំការកៅស៊ូមេមត់

+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

មាត្រា ២១ ._ ចំណាយនៃ ចំការកៅស៊ូមេមត់ រួមមាន :

+ ចំណាយប្រព្រឹត្តិសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

មាត្រា ២២ ._ ចំការកៅស៊ូមេមត់ អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សំរាប់តំរូវការរបស់ខ្លួន ។

មាត្រា ២៣ ._ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល ចំការកៅស៊ូមេមត់ ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ ចំការកៅស៊ូមេមត់ មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

មាត្រា ២៤ ._ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

មាត្រា ២៥._ រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ចំការកៅស៊ូមេមត់ ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)
- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូមេមត់
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

មាត្រា ២៦ ._ ត្រូវបានដាក់ឲ្យនៅអម ចំការកៅស៊ូមេមត់ នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៥

## អវសានបញ្ញត្តិ

មាត្រា ២៧ ._ បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៨ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
ឈាវ សុង

***

## អនុក្រឹត្យលេខ ១៨ អនក្រ.បក

## ស្តីពីការបង្កើត ចំការកៅស៊ូជប់

## ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ។

## សំរេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.**_ ត្រូវបានកែប្រែអង្គភាពស្វយ័តភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូជុបឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូជុប** សរសេរកាត់ "ច ក ជ" ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ចំការកៅស៊ូជុប** មានទីស្នាក់ការនៅភូមិជុប ឃុំជុប ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម
- **ចំការកៅស៊ូជុប** គឺជានីតិបុគ្គលប្រកបដោយស្វយ័តភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

**មាត្រា ២ .**_ **ចំការកៅស៊ូជុប** មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម-ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ **ចំការកៅស៊ូជុប** មានភារកិច្ច និង កាតព្វកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់ គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការលើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការធ្វើអាជីវកម្ម-ផលិតកម្ម ។

- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មជ័រកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិដ្ឋាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

មាត្រា ៣ .- ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ចំការកៅស៊ូជុប ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ ចំការកៅស៊ូជុប ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង់ និងមានការរីកចំរើន ។

មាត្រា ៤ .- ចំការកៅស៊ូជុប ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើតចំការកៅស៊ូជុប

៣-លក្ខន្តិកៈ ចំការកៅស៊ូជុប

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

មាត្រា ៥ .- ចំការកៅស៊ូជុប ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

មាត្រា ៦ .- ដើមទុនដំបូងនៃ ចំការកៅស៊ូជុប ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន ចំការកៅស៊ូជប់ ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៧ .- បុគ្គលិករបស់ ចំការកៅស៊ូជប់ ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូជុប។

បុគ្គលិករបស់ ចំការកៅស៊ូជុប ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២

## ការដឹកនាំនិងគ្រប់គ្រង

មាត្រា ៨ ._ ចំការកៅស៊ូជុប ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + ប្រធានអគ្គនាយក ចំការកៅស៊ូជុប | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តកំពង់ចាម ឬតំណាង | ១ រូប | ជាសមាជិក |
| + តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ | ១ រូប | ជាសមាជិក |
| + តំណាងនិយោជិតរបស់ ចំការកៅស៊ូជប់ | ១ រូប | ជាសមាជិកស្វ័យប្រវត្តិ |

មាត្រា ៩ ._ -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរ ដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត ចំការកៅស៊ូជុប

មាត្រា ១០ ._ ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម ចំការកៅស៊ូជុប ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី ៖

១- ផ្ដល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ ចំការកៅស៊ូជុប ។

៤- សម្រេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ ចំការកៅស៊ូជុប ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល ចំការកៅស៊ូជុប ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ ចំការកៅស៊ូជុប តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ។

មាត្រា ១១.- ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាយក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាយក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំង ឯកសារទាក់ទិនទាំងឡាយ ត្រូវធ្វើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារ កូរ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការបែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២._ សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក ចំការកៅស៊ូជុប ។

មាត្រា ១៣._ ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ចំការកៅស៊ូជុប និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

មាត្រា ១៤._ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ :

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលតាមតំណាក់កាលនីមួយៗ បធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ ចំការកៅស៊ូជុប ។

២-ទទួលដឹកនាំ ចំការកៅស៊ូជុប លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ ចំការកៅស៊ូជុប ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ ចំការកៅស៊ូជុប ដោយអនុវត្តតាមលក្ខន្តិកៈ បុគ្គលិក ឬ ច្បាប់ជាធរមាន និងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ ចំការកៅស៊ូជុប ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់តវ៉ាការពារក្តីឲ្យ ចំការកៅស៊ូជុប និងការប្តឹងជំទាស់ផ្សេងៗ ។

មាត្រា ១៥ ._ លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៦ ._ ការចុះ និង ការអនុវត្តន៍កិច្ចសន្យាដោយ ចំការកៅស៊ូជូប ត្រូវគោរពតាមប្រែបបទ្ធនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧ ._ ចំការកៅស៊ូជូប កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ ចំការកៅស៊ូជូប ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ចំការកៅស៊ូជូប ។

-សេវាកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាស់សាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ ចំការកៅស៊ូជុប ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ ចំការកៅស៊ូជុប ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ ចំការកៅស៊ូជុប ។

មាត្រា ២០ ._ ធនធាននៃ ចំការកៅស៊ូជុប ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ ចំការកៅស៊ូជុប ។

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុអចលនវត្ថុរបស់ ចំការកៅស៊ូជុប ។

+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

មាត្រា ២១ ._ ចំណាយនៃ ចំការកៅស៊ូជុប រួមមាន :

+ ចំណាយប្រក្រតីសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

មាត្រា ២២ ._ ចំការកៅស៊ូជុប អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

មាត្រា ២៣._ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល ចំការកៅស៊ូជុប ទទួលបានក្រោយ

ពីការទូទាត់ ស្របតាមវិធានគណនេយ្យ ចំការកៅស៊ូជុប មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះ ឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

**មាត្រា ២៤ .-** រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៥ .-** រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ចំការកៅស៊ូជុប ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៨)
- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូជុប
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

**មាត្រា ២៦ .-** ត្រូវបានដាក់ឲ្យនៅអម ចំការកៅស៊ូជុប នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាស សាធារណៈ ។

## ជំពូក ៥

## អវសានបញ្ញត្តិ

**មាត្រា ២៧ .-** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៨ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន

មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
**ឈាវ សុខ**

★★★

**អនុក្រឹត្យលេខ ១៥ អនក្រ.បក**

**ស្តីពីការបង្កើត ចំការកៅស៊ូក្រែក**

**ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

**សំរេច**

**ជំពូក ១**

**បទបញ្ញត្តិទូទៅ**

មាត្រា ១._ ត្រូវបានកែប្រែអង្គភាពស្វ័យភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូក្រែកឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូក្រែក** សរសេរកាត់ "ច ក ក " ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ចំការកៅស៊ូក្រែក** មានទីស្នាក់ការស្ថិតនៅទីរួមស្រុកពញាក្រែក ខេត្តកំពង់ចាម ។
- **ចំការកៅស៊ូក្រែក** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

មាត្រា ២ ._ **ចំការកៅស៊ូក្រែក** មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ **ចំការកៅស៊ូក្រែក** មានភារកិច្ច និង កាតព្វកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការបើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធក្នុងការធ្វើអាជីវកម្ម-ផលិតកម្ម ។

- លើកកំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មជាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ ។
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិដ្ឋាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

មាត្រា ៣ ._ ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ចំការកៅស៊ូក្រែក ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នានឹងពាណិជ្ជកម្មទូទៅ ។ ក្នុងន័យនេះ ចំការកៅស៊ូក្រែក ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង្ស និងមានការរីកចំរើន ។

មាត្រា ៤ ._ ចំការកៅស៊ូក្រែក ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត ចំការកៅស៊ូក្រែក

៣-លក្ខន្តិកៈ ចំការកៅស៊ូក្រែក

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

មាត្រា ៥ ._ ចំការកៅស៊ូក្រែក ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

មាត្រា ៦ ._ ដើមទុនដំបូងនៃ ចំការកៅស៊ូក្រែក ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន ចំការកៅស៊ូក្រែក ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៧ ._ បុគ្គលិករបស់ ចំការកៅស៊ូក្រែក ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូក្រែក ។

បុគ្គលិករបស់ ចំការកៅស៊ូក្រែក ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២
## ការដឹកនាំនិងគ្រប់គ្រង

មាត្រា ៨ .- ចំការកៅស៊ូគ្រែក ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

+ ប្រធានអគ្គនាយក ចំការកៅស៊ូគ្រែក ១ រូប ជាប្រធាន
+ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១ រូប ជាសមាជិក
+ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប ជាសមាជិក
+ តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១ រូប ជាសមាជិក
+ អភិបាលខេត្តកំពង់ចាម ឬតំណាង ១ រូប ជាសមាជិក
+ តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ ១ រូប ជាសមាជិក
+ តំណាងនិយោជិតរបស់ ចំការកៅស៊ូគ្រែក ១ រូប ជាសមាជិកស្វ័យប្រវត្តិ

មាត្រា ៩ .- -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត ចំការកៅស៊ូគ្រែក ។

មាត្រា ១០ .- ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម ចំការកៅស៊ូគ្រែក ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី :

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ ចំការកៅស៊ូក្រែក ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ ចំការកៅស៊ូក្រែក ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល ចំការកៅស៊ូក្រែក ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ ចំការកៅស៊ូក្រែក តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

មាត្រា ១១ .- -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាយក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាយក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាយករួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេការប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២._ សេចក្ដីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរបំផុតចាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធាននិងអគ្គនាយក ចំការកៅស៊ូក្រែក ។

មាត្រា ១៣._ ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ចំការកៅស៊ូក្រែក និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

មាត្រា ១៤._ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ ៖

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមដំណាក់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ ចំការកៅស៊ូក្រែក ។

២-ទទួលដឹកនាំ ចំការកៅស៊ូក្រែក លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ ចំការកៅស៊ូក្រែក ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ផ្ទេរ ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រាបណ្ដាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ ចំការកៅស៊ូក្រែក ដោយអនុវត្តតាមលក្ខន្តិកៈ បុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ ចំការកៅស៊ូក្រែក ចំពោះមុខតុលាការ និងសាលាជំរះក្ដីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ដាំការពារក្ដីឲ្យ ចំការកៅស៊ូក្រែក និងការប្ដឹងជំទាស់ផ្សេងៗ ។

មាត្រា ១៥ ._ លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុម ប្រឹក្សាភិបាល ។

មាត្រា ១៦.- ការចុះ និង ការអនុវត្តន៍កិច្ចសន្យាដោយ ចំការកៅស៊ូគ្រែក ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧.- ចំការកៅស៊ូគ្រែក កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញត្តគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨.- -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ ចំការកៅស៊ូគ្រែក ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ចំការកៅស៊ូគ្រែក ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ ចំការកៅស៊ូកំពង់ត្រាច ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ ចំការកៅស៊ូកំពង់ត្រាច ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ចំការកៅស៊ូកំពង់ត្រាច ។

មាត្រា ២០ ._ ធនធាននៃ ចំការកៅស៊ូកំពង់ត្រាច ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ ចំការកៅស៊ូកំពង់ត្រាច ។

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ចំការកៅស៊ូកំពង់ត្រាច ។

+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

មាត្រា ២១ ._ ចំណាយនៃ ចំការកៅស៊ូកំពង់ត្រាច រួមមាន :

+ ចំណាយប្រក្រតីសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

មាត្រា ២២ ._ ចំការកៅស៊ូកំពង់ត្រាច អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

មាត្រា ២៣._ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល ចំការកៅស៊ូកំពង់ត្រាច ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ ចំការកៅស៊ូកំពង់ត្រាច មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្រមទៅតាមលក្ខណៈច្បាប់ ។

មាត្រា ២៤ ._ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### ជំពូក ៤

### ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៥ ._** រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ចំការកៅស៊ូក្រែក ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)
- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូក្រែក
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

**មាត្រា ២៦ :** ត្រូវបានដាក់ឲ្យនៅអមចំការកៅស៊ូក្រែក នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

### ជំពូក ៥

### អវសានបញ្ញត្តិ

**មាត្រា ២៧ ._** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៨ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
**ឈា សុង**

★★★

## អនុក្រឹត្យលេខ ១៦ អនក្រ.បក

## ស្តីពីការបង្កើតចំការកៅស៊ូតាមជាំង

## ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១-៩៦-១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

## សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

មាត្រា ១._ ត្រូវបានកែប្រែអង្គភាពស្វ័យភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូតាមជាំងឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា ចំការកៅស៊ូតាម

ជាំខ គឺស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ចំការកៅស៊ូពាមជាំខ មានទីស្នាក់ការស្ថិតនៅ ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ។ ចំការកៅស៊ូពាមជាំខ គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ ។

មាត្រា ២._ ចំការកៅស៊ូពាមជាំខ មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ ចំការកៅស៊ូពាមជាំខ មានភារកិច្ច និងភារពកិច្ចដូចខាងក្រោម៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតម្រង់ទិសដោយរាជរដ្ឋាភិបាល គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ។

- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្រយន្ត ពេលខ្លី មធ្យម វែង។

- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច។

- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ។

- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការលើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធក្នុងការធ្វើអាជីវកម្ម-ផលិតកម្ម។

- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។

- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ ។

- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។

- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិស្ថាន ។

- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

មាត្រា ៣._ ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ចំការកៅស៊ូពាមជាំខ ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការ ដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ ចំការកៅស៊ូពាមជាំខ ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ

ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង្ស និងមានការរីកចំរើន ។

**មាត្រា ៤ .-** ចំការកៅស៊ូចំការពាមជាំង ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត ចំការកៅស៊ូពាមជាំង

៣-លក្ខន្តិកៈ ចំការកៅស៊ូពាមជាំង

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

**មាត្រា ៥ .-** ចំការកៅស៊ូពាមជាំង ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ៦ .-** ដើមទុនដំបូងនៃ ចំការកៅស៊ូពាមជាំង ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន ចំការកៅស៊ូពាមជាំង ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

**មាត្រា ៧ .-** បុគ្គលិករបស់ ចំការកៅស៊ូពាមជាំង ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូពាមជាំង ។

បុគ្គលិករបស់ ចំការកៅស៊ូពាមជាំង ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២

## ការដឹកនាំនិងគ្រប់គ្រង

**មាត្រា ៨ .-** ចំការកៅស៊ូពាមជាំង ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + ប្រធានអគ្គនាយក ចំការកៅស៊ូពាមជាំង | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តកំពង់ចាម ឬតំណាង | ១ រូប | ជាសមាជិក |

+ តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ ១ រូប ជាសមាជិក

+ តំណាងនិយោជិតរបស់ ចំការកៅស៊ូតាមជាំង ១ រូប ជាសមាជិកស្វ័យប្រវត្តិ

មាត្រា ៩ .- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។

តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត ចំការកៅស៊ូតាមជាំង

មាត្រា ១០ .- ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម ចំការកៅស៊ូតាមជាំង ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី ៖

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ចំការកៅស៊ូតាមជាំង ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ ចំការកៅស៊ូតាមជាំង ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល ចំការកៅស៊ូតាមជាំង ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និង បែបបទដូចមានគ្រោងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ ចំការកៅស៊ូតាមជាំង តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មនៃសហគ្រាសសាធារណៈ ។

**មាត្រា ១១ ._** -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេការប្រជុំត្រូវលើទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

**មាត្រា ១២._** សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក ចំការកៅស៊ូចាមជាំខ ។

**មាត្រា ១៣ ._** ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ចំការកៅស៊ូចាមជាំខ និងត្រូវបានតែងតាំង សំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ។

មាត្រា ១៤._ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ៖

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមតំណាក់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ **ចំការកៅស៊ូពាមជាំង** ។

២-ទទួលដឹកនាំ **ចំការកៅស៊ូពាមជាំង** លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ **ចំការកៅស៊ូពាមជាំង** ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាផ្ទេរភារៈ បណ្ដោះអាសន្នការងារឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **ចំការកៅស៊ូពាមជាំង** ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្របតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ **ចំការកៅស៊ូពាមជាំង** ចំពោះមុខតុលាការ និងសាលាជំរះក្ដីគ្រប់ជាន់ថ្នាក់ក្នុងការលើកចោទប្រកាន់ពាក់ព័ន្ធការពារក្ដីឲ្យ **ចំការកៅស៊ូពាមជាំង** និងការប្ដឹងជំទាស់ផ្សេងៗ ។

មាត្រា ១៥ ._ លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៦ ._ ការតុះ និង ការអនុវត្តកិច្ចសន្យាដោយ **ចំការកៅស៊ូពាមជាំង** ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧ ._ **ចំការកៅស៊ូពាមជាំង** កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញត្តិគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ៗ

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) លើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ ចំការកៅស៊ូតាមដាំង ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ចំការកៅស៊ូតាមដាំង ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បី សុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ធាតុការសំរាប់ដំណើរការនៃ **ចំការកៅស៊ូតាមជាំង** ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ **ចំការកៅស៊ូតាមជាំង** ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូតាមជាំង** ។

**មាត្រា ២០ .**_ ធនធាននៃ **ចំការកៅស៊ូតាមជាំង** ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ **ចំការកៅស៊ូតាមជាំង** ។

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុនិង អចលនវត្ថុរបស់ **ចំការកៅស៊ូតាមជាំង** ។

+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

**មាត្រា ២១ .**_ ចំណាយនៃ **ចំការកៅស៊ូតាមជាំង** រួមមាន :

+ ចំណាយប្រក្រតីសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

**មាត្រា ២២ .**_ **ចំការកៅស៊ូតាមជាំង** អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា ២៣ .**_ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រាក់ចំណេញដែល **ចំការកៅស៊ូតាមជាំង** ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ **ចំការកៅស៊ូតាមជាំង** មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះ ឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

**មាត្រា ២៤ .**_ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា ២៥ .**_ រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល **ចំការកៅស៊ូតាមជាំង** ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)

- របាយការណ៍ស្តីពីសកម្មភាព-ឥណ្ឌូការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូពាមជាំង
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្ថាប័នការគណនី ។

មាត្រា ២៦ ._ ត្រូវបានដាក់ឲ្យនៅអម ចំការកៅស៊ូពាមជាំង នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៥

## អវសានបញ្ញត្តិ

មាត្រា ២៧ ._ បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៨ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

| | |
|---|---|
| ទេសរដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ហត្ថលេខា | ហត្ថលេខា |
| គាត ឈន់ | ឈា សុខ |

★★★

## អនុក្រឹត្យលេខ ១៧ អនក្រ.បក
## ស្តីពីការបង្កើត ចំការកៅស៊ូបឹងកេត
## ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានបានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

### សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

**មាត្រា ១.**_ ត្រូវបានកែប្រែអង្គភាពស្វ័យភាពសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូបឹងកេតឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូបឹង**

កេត សរសេរកាត់ "ច ក ម ក" ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ចំការកៅស៊ូមីមកេត មានទីស្នាក់ការស្ថិតនៅឃុំព្រៃកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។
- ចំការកៅស៊ូមីមកេត គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

មាត្រា ២ ._ ចំការកៅស៊ូមីមកេត មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះពង្រីកកៅស៊ូ ដើម្បីបំពេញ នូវកម្មវត្ថុខាងលើនេះ ចំការកៅស៊ូមីមកេត មានភារកិច្ច និង ភារកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុននៃរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការលើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការធ្វើអាជីវកម្ម-ផលិតកម្ម ។
- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ ហើយស្នើរ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ ។
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិស្ថាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តទៅរបស់សហគ្រាស ។

មាត្រា ៣ ._ ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ចំការកៅស៊ូមីមកេត ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ ចំការកៅស៊ូមីមកេត ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ

ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង់ និងមានការរីកចំរើន ។

មាត្រា ៤ ._ ចំការកៅស៊ូបឹងកេត ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត ចំការកៅស៊ូបឹងកេត

៣-លក្ខន្តិកៈ ចំការកៅស៊ូបឹងកេត

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

មាត្រា ៥ ._ ចំការកៅស៊ូបឹងកេត ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

មាត្រា ៦ ._ ដើមទុនដំបូងនៃ ចំការកៅស៊ូបឹងកេត ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន ចំការកៅស៊ូបឹងកេត ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៧ ._ បុគ្គលិករបស់ ចំការកៅស៊ូបឹងកេត ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូបឹងកេត ។

បុគ្គលិករបស់ ចំការកៅស៊ូបឹងកេត ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២

## ការដឹកនាំនិងគ្រប់គ្រង

មាត្រា ៨ ._ ចំការកៅស៊ូបឹងកេត ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| + ប្រធានអគ្គនាយក ចំការកៅស៊ូបឹងកេត | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តកំពង់ចាម ឬតំណាង | ១ រូប | ជាសមាជិក |

+ តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ ១ រូប ជាសមាជិក

+ តំណាងនិយោជិតរបស់ ចំការកៅស៊ូមីចកេត ១ រូប ជាសមាជិកស្ម័គ្រប្រវត្តិ

មាត្រា ៩ ._ -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។

- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិតចំការកៅស៊ូមីចកេត ។

មាត្រា ១០ ._ ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម ចំការកៅស៊ូមីចកេត ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី :

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ចំការកៅស៊ូមីចកេត ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ ចំការកៅស៊ូមីចកេត ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល ចំការកៅស៊ូមីចកេត ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និង បែបបទដូចមានគ្រោងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ ចំការកៅស៊ូមីចកេត តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

មាត្រា ១១ ._ -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាយក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាយក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេការប្រជុំត្រូវលើទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២._ សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក **ចំការកៅស៊ូចឹបកេត** ។

មាត្រា ១៣._ ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ **ចំការកៅស៊ូចឹបកេត** និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

មាត្រា ១៤._ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ ៖

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមតំណាក់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ ចំការកៅស៊ូមឹមកេត ។

២-ទទួលដឹកនាំ ចំការកៅស៊ូមឹមកេត លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ ចំការកៅស៊ូមឹមកេត ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជ្រួតព្រាបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិករបស់ ចំការកៅស៊ូមឹមកេត ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្រេមតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ ចំការកៅស៊ូមឹមកេត ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ឥវ៉ាការពារក្តីឲ្យ ចំការកៅស៊ូមឹមកេត និងការប្តឹងជំទាស់ផ្សេងៗ ។

មាត្រា ១៥ ._ លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៦ ._ ការចុះ និង ការអនុវត្តន៍កិច្ចសន្យាដោយ ចំការកៅស៊ូមឹមកេត ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧ ._ ចំការកៅស៊ូមឹមកេត កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញត្តគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកត/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ ចំការកៅស៊ូមីមត ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់អំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ចំការកៅស៊ូមីមត ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ ៖

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ ចំការកៅស៊ូមីមត ។

៣- ការប៉ាន់ស្មានថ្លៃទិញ លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ ចំការកៅស៊ូមីមត ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ ចំការកៅស៊ូមីមត ។

មាត្រា ២០ ._ ធនធាននៃ ចំការកៅស៊ូចឹងគេត ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។

+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ ចំការកៅស៊ូចឹងគេត ។

+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ចំការកៅស៊ូចឹងគេត ។

+ ប្រាក់បានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

មាត្រា ២១ ._ ចំណាយនៃ ចំការកៅស៊ូចឹងគេត រួមមាន :

+ ចំណាយប្រក្រតីសំរាប់ដំណើរការ

+ ចំណាយវិនិយោគ

+ ចំណាយសាងសង់ និងជួសជុល

+ សងបំណុល

+ ចំណាយផ្សេងៗ

មាត្រា ២២ ._ ចំការកៅស៊ូចឹងគេត អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

មាត្រា ២៣._ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល ចំការកៅស៊ូចឹងគេត ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ ចំការកៅស៊ូចឹងគេត មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

មាត្រា ២៤ ._ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

មាត្រា ២៥._ រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ចំការកៅស៊ូចឹងគេត ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៩)
- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូចឹងគេត
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

មាត្រា ២៦ ._ ត្រូវបានដាក់ឲ្យនៅអម ចំការកៅស៊ូចឹងគេត នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជាក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

## ជំពូក ៥

## អវសានបញ្ញត្តិ

មាត្រា ២៧ ._ បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៨ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
**គាត ឈន់**

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
**ឈា សុខ**

★★★

## អនុក្រឹត្យលេខ ១៨ អនក្រ.បក

## ស្តីពីការបង្កើត ចំការកៅស៊ូចំការអណ្តូង

## ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៥ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

## សម្រេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.**_ ត្រូវបានកែប្រែអង្គភាពស្វ័យភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូចំការអណ្តូងឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា **ចំការកៅស៊ូចំការអណ្តូង** សរសេរកាត់ " ច ក ច អ " ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ចំការកៅស៊ូចំការអណ្តូង** មានទីស្នាក់ការស្ថិតនៅឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម ។
- **ចំការកៅស៊ូចំការអណ្តូង** គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ ។

មាត្រា ២ ._ ចំការកៅស៊ូចំការអណ្ដូង មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ ចំការកៅស៊ូចំការអណ្ដូង មានភារកិច្ច និង ភាតព្វកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំរោងគ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានក្រិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្តិធិ ការផុតខ្ទប់ ការបើកដាក់ ការឆ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការធ្វើអាជីវកម្ម-ផលិតកម្ម ។
- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារ មធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ ។
- ជាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្ដីពីការការពារធនធានធម្មជាតិ និងបរិស្ថាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

មាត្រា ៣ ._ ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ចំការកៅស៊ូចំការអណ្ដូង ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកបកិច្ចការ ដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ ចំការកៅស៊ូចំការអណ្ដូង ត្រូវទទួលស្វ័យភាពយ៉ាងធំទូលាយ ដើម្បីដឹកនាំចាត់សកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាង ណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង្ស និងមានការរីកចំរើន ។

មាត្រា ៤ ._ ចំការកៅស៊ូចំការអណ្ដូង ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ ៖

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត ចំការកៅស៊ូចំការអណ្តូង

៣-លក្ខន្តិកៈ ចំការកៅស៊ូចំការអណ្តូង

៤-ច្បាប់ និងបទបញ្ញាត្តិពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

មាត្រា ៥ ._ ចំការកៅស៊ូចំការអណ្តូង ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

មាត្រា ៦ ._ ដើមទុនដំបូងនៃ ចំការកៅស៊ូចំការអណ្តូង ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន ចំការកៅស៊ូចំការអណ្តូង ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៧._ បុគ្គលិករបស់ ចំការកៅស៊ូចំការអណ្តូង ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូចំការអណ្តូង ។

បុគ្គលិករបស់ ចំការកៅស៊ូចំការអណ្តូង ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២

## ការដឹកនាំនិងគ្រប់គ្រង

មាត្រា ៨ ._ ចំការកៅស៊ូចំការអណ្តូង ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម ÷

+ ប្រធានអគ្គនាយក ចំការកៅស៊ូចំការអណ្តូង ១ រូប ជាប្រធាន
+ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១ រូប ជាសមាជិក
+ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប ជាសមាជិក
+ តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ១ រូប ជាសមាជិក
+ អភិបាលខេត្តកំពង់ចាម ឬតំណាង ១ រូប ជាសមាជិក
+ តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ ១ រូប ជាសមាជិក
+ តំណាងនិយោជិតរបស់ ចំការកៅស៊ូចំការអណ្តូង ១ រូប ជាសមាជិកស្វ័យប្រវត្តិ

មាត្រា ៩._ -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍

ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។
- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត ចំការកៅស៊ូចំការអណ្ដូង ។

មាត្រា ១០.- ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម ចំការកៅស៊ូចំការអណ្ដូង ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី ៖

១- ផ្ដល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្ដល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ ចំការកៅស៊ូចំការអណ្ដូង ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ ចំការកៅស៊ូចំការអណ្ដូង ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗសំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្ដល់ការយល់ព្រមលើកិច្ចសន្យាដែល ចំការកៅស៊ូចំការអណ្ដូង ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងរបៀបបទដូចមានគ្រោងក្នុងបទបញ្ញត្តិជាធរមាន ស្ដីពីកិច្ចសន្យាដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ ចំការកៅស៊ូចំការអណ្ដូង តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

មាត្រា ១១ ._ -ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអំពីប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

-ទោះយ៉ាងណាយក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាយក់រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេអង្គប្រជុំត្រូវលើកទៅ ១៥ថ្ងៃក្រោយទៀត ដើម្បីពិភាក្សាឡើងវិញលើបញ្ហារបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២._ សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក ចំការកៅស៊ូចំការអណ្តូង ។

មាត្រា ១៣ ._ ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ចំការកៅស៊ូចំការអណ្តូង និងត្រូវបានតែងតាំង សំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ។

មាត្រា ១៤._ ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ :

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្តីសំរេច របស់ក្រុមប្រឹក្សាភិបាល ។ តាមដំណាក់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ ចំការកៅស៊ូចំការអណ្តូង ។

២-ទទួលដឹកនាំ ចំការកៅស៊ូចំការអណ្តូង លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និង ហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ ចំការកៅស៊ូចំការអណ្តូង ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រា បណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ ចំការកៅស៊ូចំការអណ្តូង ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្រមតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ ចំការកៅស៊ូចំការអណ្តូង ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ផងការពារក្តីឲ្យ ចំការកៅស៊ូចំការអណ្តូង និងការប្តឹងជំទាស់ផ្សេងៗ ។

មាត្រា ១៥ ._ លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុម ប្រឹក្សាភិបាល ។

មាត្រា ១៦ ._ ការចុះ និងការអនុវត្តន៍កិច្ចសន្យាដោយ ចំការកៅស៊ូចំការអណ្តូង ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧ ._ ចំការកៅស៊ូចំការអណ្តូង កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-តុល្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ **ចំការកៅស៊ូចំការអណ្តូង** ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ **ចំការកៅស៊ូចំការអណ្តូង** ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ **ចំការកៅស៊ូចំការអណ្តូង** ។

៣- ការប៉ាន់ស្មានថ្លៃទិញ លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ ចំការកៅស៊ូចំការអណ្តូង ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ ចំការកៅស៊ូចំការអណ្តូង ។

មាត្រា ២០ ._ ធនធាននៃ ចំការកៅស៊ូចំការអណ្តូង ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូងនៅពេលបង្កើត) ។
+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។
+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ ចំការកៅស៊ូចំការអណ្តូង ។
+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ចំការកៅស៊ូចំការអណ្តូង ។
+ ប្រាក់ដែលបានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

មាត្រា ២១ ._ ចំណាយនៃ ចំការកៅស៊ូចំការអណ្តូង រួមមាន :

+ ចំណាយប្រក្រតីសំរាប់ដំណើរការ
+ ចំណាយវិនិយោគ
+ ចំណាយសាងសង់ និងជួសជុល
+ សងបំណុល
+ ចំណាយផ្សេងៗ

មាត្រា ២២ ._ ចំការកៅស៊ូចំការអណ្តូង អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

មាត្រា ២៣ : ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល ចំការកៅស៊ូចំការអណ្តូង ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ ចំការកៅស៊ូចំការអណ្តូង មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

មាត្រា ២៤ ._ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤
## ការទំនាក់ទំនងជាមួយរដ្ឋ

មាត្រា ២៥ ._ រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ចំការកៅស៊ូចំការអណ្តូង ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៨)

- របាយការណ៍ស្ដីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូចំការអណ្ដូង
- របាយការណ៍ស្ដីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

មាត្រា ២៦ ._ ត្រូវបានដាក់ឲ្យនៅអម ចំការកៅស៊ូចំការអណ្ដូង នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំង ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្ដល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៥

## អវសានបញ្ញត្តិ

មាត្រា ២៧ ._ បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៨ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានយកសេចក្ដីជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ហត្ថលេខា
ឈា សុខ

★★★

# អនុក្រឹត្យលេខ ១៩ អនក្រ.បក
## ស្ដីពីការបង្កើត ចំការកៅស៊ូស្នួល
## ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តន៍ព្រះរាជាក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- តាមសំណើរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការយល់ព្រមពី គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

### សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

មាត្រា ១._ ត្រូវបានកែប្រែអង្គភាពស្វ័យភិបាលសេដ្ឋកិច្ចដែលមានឈ្មោះ ក្រុមហ៊ុនចំការកៅស៊ូស្នួលឲ្យទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ដែលពីពេលនេះតទៅមានឈ្មោះថា ចំការកៅស៊ូស្នួល

សរសេរកាត់ "ច ក ស ..." ដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ចំការកៅស៊ូស្នួល មានទីស្នាក់ការស្ថិតនៅឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ
- ចំការកៅស៊ូស្នួល គឺជានីតិបុគ្គលប្រកបដោយស្វ័យភាព ផ្នែករដ្ឋបាល និង ផ្នែកហិរញ្ញវត្ថុ

មាត្រា ២ ._ ចំការកៅស៊ូស្នួល មានកម្មវត្ថុសំខាន់គឺ ធ្វើអាជីវកម្ម-ផលិតកម្ម ដាំដុះលើវិស័យកៅស៊ូ ដើម្បីបំពេញនូវកម្មវត្ថុខាងលើនេះ ចំការកៅស៊ូស្នួល មានភារកិច្ច និង ញត្តិកិច្ចដូចខាងក្រោម ៖

- កំណត់ផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតំរង់ទិសដោយរាជរដ្ឋាភិបាល ។
- គ្រប់គ្រងទទួលខុសត្រូវ និងប្រើប្រាស់ឲ្យមានប្រសិទ្ធភាព នូវធនធានដីធ្លី ដើមកៅស៊ូ និងទ្រព្យសម្បត្តិ (ចលនទ្រព្យ និងអចលនទ្រព្យ) មានស្រាប់ដែលរដ្ឋប្រគល់ឲ្យ ។
- កសាងគំរោងផែនការ អាជីវកម្ម-ផលិតកម្ម ដាំដុះកូនកៅស៊ូ សំណង់គ្រឿងចក្ររយៈពេលខ្លី មធ្យម វែង ។
- អនុវត្តការងារអាជីវកម្ម ផលិតកម្ម និង ដាំដុះ ទៅតាមបទដ្ឋានកំរិតកំណត់នៃបច្ចេកទេសកៅស៊ូ ដើម្បីធានាបរិមាណ គុណភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ។
- ធានា និង ពង្រីកដើមទុនដែលរដ្ឋប្រគល់ឲ្យ ក្រោមរូបភាពវិនិយោគភាគហ៊ុនរបស់ខ្លួន ទៅលើការងារធ្វើអាជីវកម្ម និងពង្រីកផ្ទៃដីដាំដុះដំណាំកៅស៊ូ ។
- គ្រប់គ្រងសន្និធិ ការវេចខ្ចប់ ការលើកដាក់ ការធ្លងកាត់ និងការបំពេញបែបបទផ្សេងៗ ដែលពាក់ព័ន្ធដល់ការធ្វើអាជីវកម្ម-ផលិតកម្ម ។
- លើកគំរោងក្នុងការលក់ និងការនាំចេញផលិតផលកៅស៊ូ និងការនាំចូលនូវសំភារៈ បរិក្ខារមធ្យោបាយផ្សេងៗ សំរាប់បំរើឲ្យការងារអាជីវកម្ម-ផលិតកម្មដាំដុះកៅស៊ូ ។
- អាចប្រមូលទិញទឹកជ័រកៅស៊ូពីចំការកៅស៊ូគ្រួសារ ។
- ចាត់ចែងការងារអភិវឌ្ឍន៍ធនធានមនុស្ស និងផ្សព្វផ្សាយ ស្រាវជ្រាវបច្ចេកទេសទំនើបៗ តាមរូបភាពសហប្រតិបត្តិការ ។
- អនុវត្តច្បាប់ ស្តីពីការការពារធនធានធម្មជាតិ និងបរិដ្ឋាន ។
- ជារួមរាល់កិច្ចប្រតិបត្តិការ បច្ចេកទេស ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម ដែលពាក់ព័ន្ធដល់កម្មវត្ថុ ឬដែលចាំបាច់ដល់ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

មាត្រា ៣ ._ ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ចំការកៅស៊ូស្នួល ត្រូវប្រកាន់គោលការណ៍ និងរបៀបប្រកប កិច្ចការដូចគ្នានឹងពាណិជ្ជករទូទៅ ។ ក្នុងន័យនេះ ចំការកៅស៊ូស្នួល ត្រូវទទួលស្វ័យភាពយ៉ាង ធំទូលាយ

ដើម្បីដឹកនាំចាត់ចែងសកម្មភាពរបស់ខ្លួនក្នុងគោលដៅបំពេញបេសកកម្មឲ្យមានប្រសិទ្ធភាព និងធ្វើយ៉ាងណាឲ្យបេតិកភ័ណ្ឌរបស់ខ្លួនបានគង់វង់ និងមានការរីកចំរើន ។

មាត្រា ៤ ._ ចំការកៅស៊ូស្នួល ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិដូចតទៅ :

១-ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

២-អនុក្រឹត្យស្តីពីការបង្កើត ចំការកៅស៊ូស្នួល

៣-លក្ខន្តិកៈ ចំការកៅស៊ូស្នួល

៤-ច្បាប់ និងបទបញ្ញាពាក់ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មចំពោះបទបញ្ញត្តិទាំងឡាយ ដែលពុំផ្ទុយទៅនឹងអត្ថបទខាងលើ ។

មាត្រា ៥ ._ ចំការកៅស៊ូស្នួល ត្រូវបង់ពន្ធអាករស្របតាមច្បាប់ និងបទបញ្ញាជាធរមាន ។

មាត្រា ៦ ._ ដើមទុនដំបូងនៃ ចំការកៅស៊ូស្នួល ត្រូវកំណត់ឡើងតាមតុល្យការដំបូង ដែលបានទទួលការឯកភាពពីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន ចំការកៅស៊ូស្នួល ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៧._ បុគ្គលិករបស់ ចំការកៅស៊ូស្នួល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការដែលមានស្រាប់នៃក្រុមហ៊ុនចំការកៅស៊ូស្នួល ។

បុគ្គលិករបស់ ចំការកៅស៊ូស្នួល ត្រូវគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែកដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ។

## ជំពូក ២

## ការដឹកនាំនិងគ្រប់គ្រង

មាត្រា ៨ ._ ចំការកៅស៊ូស្នួល ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិ នៃអនុក្រឹត្យនេះ និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| + ប្រធានអគ្គនាយក ចំការកៅស៊ូស្នួល | ១ រូប | ជាប្រធាន |
| + តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ជាសមាជិក |
| + តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាសមាជិក |
| + តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| + អភិបាលខេត្តក្រចេះ ឬតំណាង | ១ រូប | ជាសមាជិក |

+ តំណាងអគ្គនាយកដ្ឋានចំការកៅស៊ូ ១ រូប ជាសមាជិក

+ តំណាងនិយោជិតរបស់ ចំការកៅស៊ូស្នួល ១ រូប ជាសមាជិកស្វ័យប្រវត្តិ

មាត្រា ៩.- -សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្មពីបទមជ្ឈិមឡើងទៅ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះ អាចបញ្ចប់បានគ្រប់ពេលវេលានិងអាចបន្តទៀតបានដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងឲ្យ ។

- តំណាងនិយោជិតត្រូវជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមនិយោជិត ចំការកៅស៊ូស្នួល

មាត្រា ១០.- ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញ ដើម្បីសំរេចក្នុងនាម ចំការកៅស៊ូស្នួល ក្នុងការរៀបចំលិខិតស្នាម និងរាល់ឯកសារផ្សេងៗ ដែលទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាសស្របតាមច្បាប់ជាធរមាន ។

ជាអាទិ៍ក្រុមប្រឹក្សាភិបាលមានតួនាទី :

១- ផ្តល់ការយល់ព្រមលើគំរោងផែនការ របស់សហគ្រាសដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសំរួលឲ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការនិងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ចំការកៅស៊ូស្នួល ។

៤- សំរេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ ចំការកៅស៊ូស្នួល ព្រមទាំងលក្ខន្តិកៈបុគ្គលិក កាំប្រាក់បៀវត្សប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិ ទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យាដែល ចំការកៅស៊ូស្នួល ជាភាគីស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដូចមានគ្រោងក្នុងបទបញ្ញត្តិជាធរមាន ស្តីពីកិច្ចសន្យាដែលចុះ ដោយសហគ្រាសសាធារណៈ ។

៦- សំរេច បង្កើត បើក ឬ បិទ ការិយាល័យ និងទីភ្នាក់ងារ គ្រប់ទីកន្លែងរបស់ ចំការកៅស៊ូស្នួល តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- សំរេចលើលទ្ធកម្ម តាមប្រកាសលេខ ៩៩៧ សហវ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលទ្ធកម្មសហគ្រាសសាធារណៈ ។

មាត្រា ១១.- ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៍នៃសហគ្រាស តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើនៃសមាជិកដែលមានបីនាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

- ទោះយ៉ាងណាយក៏ដោយ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ ។ ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់តាមការបោះឆ្នោតក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

-ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។

-របៀបវារៈនៃការប្រជុំ ព្រមទាំង ឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

-កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះណាតែមានវត្តមានសមាជិកយ៉ាងតិចប្រាំនាក់ រួមទាំងប្រធានអង្គប្រជុំផង ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើទៅ ១៥ថ្ងៃក្រោយទៀតដើម្បីពិភាក្សាឡើងវិញលើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះពុំបាច់ទាមទារកូរ៉ុមទេ ។

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើននៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេងមានចំនួនស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ ប្រធានអង្គប្រជុំត្រូវចាត់ទុកជាឧត្តមានុភាព ។

មាត្រា ១២.- សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័នដទៃទៀតដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះក្នុងរវាង ១៥ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។

កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាន សមាជិកវត្តមាន និងលេខានៃអង្គប្រជុំ ដែលជ្រើសរើសដោយប្រធានអគ្គនាយក ចំការកៅស៊ូស្នួល ។

មាត្រា ១៣ .- ប្រធានអគ្គនាយកមានភារកិច្ចជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ ចំការកៅស៊ូស្នួល និងត្រូវបានតែងតាំងសំរាប់អាណត្តិ ៣ឆ្នាំ ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

មាត្រា ១៤.- ក្រុមប្រឹក្សាភិបាលប្រគល់ជូន ប្រធានអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះប្រធានអគ្គនាយកត្រូវ ៖

១-រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលចាត់ចែងអនុវត្តរាល់សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមកំណត់កាលនីមួយៗ ប្រធានអគ្គនាយកត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ ចំការកៅស៊ូស្នួល ។

២-ទទួលដឹកនាំ ចំការកៅស៊ូស្នួល លើផ្នែករដ្ឋបាលបច្ចេកទេស អាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ ។

៣-តំណាងឲ្យ ចំការកៅស៊ូស្នួល ចំពោះមុខតតិយជនទាំងឡាយក្នុងការបំពេញលិខិតស្នាមស៊ីវិល, រដ្ឋបាល ឬ លិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤-មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ជាត្រួតត្រា បណ្តាភ្នាក់ងារឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ ចំការកៅស៊ូស្នួល ដោយអនុវត្តតាមលក្ខន្តិកៈបុគ្គលិក ឬ ច្បាប់ជាធរមាននិងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥-មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីដែលនៅក្រោមឱវាទស្រមតាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៦-តំណាងឲ្យ ចំការកៅស៊ូស្នួល ចំពោះមុខតុលាការ និងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ក្នុងករណីចោទប្រកាន់ឥវ៉ាការពារក្តីឲ្យ ចំការកៅស៊ូស្នួល និងការប្តឹងជំទាស់ផ្សេងៗ ។

មាត្រា ១៥ .- លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់ប្រធានអគ្គនាយកត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១៦ ._ ការចុះ និងការអនុវត្តន៍កិច្ចសន្យាដោយ ចំការកៅស៊ូស្នួល ត្រូវគោរពតាមបែបបទនិងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក ៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ១៧._ ចំការកៅស៊ូស្នួល កាន់កាប់គណនេយ្យរបស់ខ្លួន ដោយប្រើតួលេខជាប្រាក់រៀល ស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល ។

-ប្រធានគណនេយ្យ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ។

-គុណ្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ (ឆ្នាំបិទការិយបរិច្ឆេទ) យោងលើរបាយការណ៍នៃគណៈនេយ្យករជំនាញម្នាក់ដែលមានមុខងារជាស្នងការគណនី ។

-គុណ្យការ និងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនីត្រូវដាក់សុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាលបានពិនិត្យរួចលើឯកសារទាំងឡាយ ។ ឯកសារទាំងនេះត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាល ដើម្បីសុំមតិទៅតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

មាត្រា ១៨._ -ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់អាណត្តិ បី ការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-លាភការសំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងបន្ទុកអាជីវកម្មរបស់ ចំការកៅស៊ូស្នួល ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំនៃការិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ចំការកៅស៊ូស្នួល ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

មាត្រា ១៩ ._ រៀងរាល់ឆ្នាំមុនថ្ងៃទី០១ ខែតុលា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើគំរោងផែនការប្រចាំឆ្នាំបន្ទាប់របស់សហគ្រាស តាមសំណើរបស់ប្រធានអគ្គនាយកហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

គំរោងផែនការប្រចាំឆ្នាំត្រូវបញ្ជាក់នូវ :

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុងសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃ ចំការកៅស៊ូស្នួល ។

៣- ការប៉ាន់ស្មានថ្លៃទិញ,លក់ មុខទំនិញដែលស្ថិតក្នុងអាជីវកម្ម សេវាកម្មរបស់ ចំការកៅស៊ូស្នួល ។

៤- លក្ខណៈវិនិច្ឆ័យសំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ ចំការកៅស៊ូស្នួល ។

មាត្រា ២០ ._ ធនធាននៃ ចំការកៅស៊ូស្នួល ជាអាទិ៍មាន :

+ ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (គុណ្យការដំបូងនៅពេលបង្កើត) ។

+ ប្រាក់ដើមទុនដែលរដ្ឋអាចផ្តល់ឲ្យបន្ថែម ។
+ ប្រាក់ចំណូលផ្សេងៗគ្រប់ប្រភេទបានមកពីសកម្មភាពរបស់ ចំការកៅស៊ូស្នួល ។
+ ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ចំការកៅស៊ូស្នួល ។
+ ប្រាក់ដែលបានមកពីការខ្ចីបុល និង ប្រាក់អំណោយផ្សេងៗ ។

មាត្រា ២១ ._ ចំណាយនៃ ចំការកៅស៊ូស្នួល រួមមាន :
+ ចំណាយប្រក្រតីសំរាប់ដំណើរការ
+ ចំណាយវិនិយោគ
+ ចំណាយសាងសង់ និងជួសជុល
+ សងបំណុល
+ ចំណាយផ្សេងៗ

មាត្រា ២២ ._ ចំការកៅស៊ូស្នួល អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់ តំរូវការរបស់ខ្លួន ។

មាត្រា ២៣._ ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេចពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រាក់ចំណេញដែល ចំការកៅស៊ូស្នួល ទទួលបានក្រោយពីការទូទាត់ ស្របតាមវិធានគណនេយ្យ ចំការកៅស៊ូស្នួល មានសិទ្ធិប្រើប្រាស់ប្រាក់ចំណេញនេះ ឲ្យសមស្របទៅតាមលក្ខណៈច្បាប់ ។

មាត្រា ២៤ ._ រដ្ឋធានាតែចំពោះបំណុលណាដែលមានការយល់ព្រមជាមុន ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

មាត្រា ២៥ ._ រយៈពេល១៥ថ្ងៃយ៉ាងយូរបំផុតក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ចំការកៅស៊ូស្នួល ត្រូវផ្ញើជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារ ដូចខាងក្រោមនេះ ÷
- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងផែនការរបស់សហគ្រាស (ដូចមានចែងក្នុងមាត្រា ១៧)
- របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ចំការកៅស៊ូស្នួល
- របាយការណ៍ស្តីពីការត្រួតពិនិត្យ របស់ស្នងការគណនី ។

មាត្រា ២៦ ._ ត្រូវបានដាក់ឲ្យនៅអមុ ចំការកៅស៊ូស្នួល នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ដែលត្រូវតែងតាំង ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំ របស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្មដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ

ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៥

## អវសានបញ្ញត្តិ

**មាត្រា ២៧.-** បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៨.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរខេត្តក្រចេះ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

| | |
|---|---|
| ទេសរដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ហត្ថលេខា | ហត្ថលេខា |
| គាត ឈន់ | ឈា សុខ |

***

## អនុក្រឹត្យលេខ ៦៦ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទទួលយល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន